# បញ្ហាកង្វល់របស់យុវវ័យ
# អំពី មេរោគអេដស៍/ជំងឺអេដស៍ និង ជំងឺកាមរោគ
# តាមរយៈប្រព័ន្ធទូរស័ព្ទកម្មវិធីរបស់សមាគមឥន្ទធនូ



ព្រឹត្តិប័ត្រព័ត៌មាន, លេខទី១, ចេញខែ វិច្ឆិកា ឆ្នាំ ២០១០

សមាគមឥន្ទធនូបានចូលរួមក្នុងការបង្ការថែទាំ និងព្យាបាលជំងឺអេដស៍នៅកម្ពុជា តាមរយៈដំណើរការការពិភាក្សាតាមប្រព័ន្ធទូរស័ព្ទដែលបានចាប់ផ្តើមនៅខែសីហា ឆ្នាំ ២០០០។ ប្រព័ន្ធទូរស័ព្ទនេះបង្កើតឡើងដើម្បីផ្តល់ជូននូវការប្រឹក្សាយោបល់ និងការផ្តល់ព័ត៌មានស្តីអំពីការឆ្លង-ការការពារ និងការថែទាំមេរោគអេដស៍/ ជំងឺអេដស៍, ជំងឺកាមរោគដោយរក្សាការសំងាត់ និងមានលក្ខណៈអនាមិកព្រមទាំងពតិមានស្តីពី និងសុខភាពបន្តពូជដល់ប្រជាជនកម្ពុជា ជាពិសេសគឺយុវវ័យដែលមានអាយុតិចជាង ២៥ឆ្នាំ ។ ឥន្ទធនូបានចាប់ផ្តើមដំណើរការសេវានេះពីទូរស័ព្ទចំនួនពីរខ្សែក្នុងដំណាក់កាលដំបូងរហូតពង្រីកដល់បួនខ្សែគិត ត្រឹមខែកញ្ញាឆ្នាំ ២០១០ នេះដោយរួមទាំងប្រព័ន្ធទូរស័ព្ទថ្មីមួយខ្សែទៀតសំរាប់ទំនាក់ទំនងពិភាក្សាអំពីមធ្យោបាយពន្យារកំនើត និងជំរើសនៃការមានផ្ទៃពោះ។

ដើម្បីគ្រប់គ្រងគុណភាព រាល់ការហៅទូរសព្ទ័ចូលទាំងអស់ត្រូវបានកត់ត្រាដោយស្វ័យប្រវត្តិក្នុងប្រពន្ធ័ទិន្នន័យរបស់ទូរស័ព្ទ។ ក្រៅពីនេះ ពតិមានទាក់ទងទៅនឹងអតិថិជន និងសំនួររបស់គាត់ត្រូវបានកត់ត្រាទុកជាលំអិតតាមប្រពន្ធ័ពតិមានវិទ្យា ដោយជ្រើសរើសយកជាស្វ័យប្រវត្តិនូវរាល់ទូរសព្ទ័ដែលហៅចូលទី៣ (Every third calls) ក្នុងចំណោមទូរសព្ទ័ហៅចូលទាំងអស់។ ការកត់ត្រាត្រូវបានធ្វើឡើងដោយអ្នកផ្តល់ប្រឹក្សាក្នុងកំលុងពេលពិភាក្សា ដោយប្រើប្រាស់ទំរង់ពិសេស (Check List) រៀបចំដោយអ្នកជំនាញផ្នែកស្ថិតិរួចបញ្ចូលទៅក្នុងប្រព័ន្ធព័ត៌មានរបស់ឥន្ទធនូនឹងបញ្ជូនទៅធ្វើការវិភាគទិន្នន័យ ដោយប្រើកម្មវិធីវិភាគដែលមានលក្ខណៈជាស្ថិតិ (statistic, Epi Info Porgram) ។

ក្នុងព្រឹត្តិប័ត្រទី១នេះឥន្ទធនូមានបំណងចែករំលែកនូវព័ត៌មានដ៏មានសារៈសំខាន់មួយចំនួនដកស្រង់ពីការវិភាគទិន្នន័យពីប្រព័ន្ធព័ត៌មានវិទ្យារបស់កម្មវិធីទូរសព្ទ័ឥន្ទធនូ។ ព្រឹត្តិប័ត្រនេះនឹងបង្ហាញជូននូវព័ត៌មានដែលទាក់ទងទៅនឹងចំងល់របស់យុវវ័យដែលមានអាយុពី ១៥ ដល់ ២៤ ឆ្នាំ បានទូរស័ព្ទមកពិភាក្សាក្នុងកំឡុងពីខែមករា ដល់ មិថុនា ឆ្នាំ ២០១០ នេះ។ លទ្ធផលនៃការវិភាគដែលនឹងបង្ហាញជូនខាងក្រោមនេះត្រូវបានធ្វើឡើងដោយក្នុងចំណោមចំនួនទូរសព្ទ័ពីយុវវ័យ ៤,២១៤ ដែលតំណាង អោយមួយភាគបី (៣៣ ភាគរយ)នៃចំនួន ទូរសព្ទ័ចូលសរុប ១២,៨៧៤ របស់អតិថិជនទាំងអស់។

## ព័ត៌មានរបស់អតិថិជនដែលទូរសព្ទ័ចូលកម្មវិធី ( 33%, 4214 )

### ភេទរបស់អតិថិជន

ចាប់ពីខែមករាដល់មិថុនាឆ្នាំ២០១០, ក្នុងចំនោមអ្នកទូរសព្ទ័ចូលកម្មវិធីដែលបានកត់ត្រាទុកចំនួន ៤,២១៤ មាន៥២,៧0% ( 33%, 2221 ) ជាយុវវ័យដែលមានអាយុ ពី ១៥ ទៅ ២៤ ឆ្នាំ។ ក្នុងក្រុមនេះមាន២ភាគ៣ជាបុរស និង ១ភាគ៣ជាស្ត្រី (រូបភាពទី១ )។ ក្នុងនេះដែរមានក្រុមបុរសស្រឡាញ់បុរស ៤,៣% ក្នុងចំណោមក្រុមយុវវ័យបុរសទាំងអស់ដែលបានទូរសព្ទ័ចូលមក។ ស្ត្រីដែលបំរើការងារនៅកន្លែងកំសាន្តសប្បាយ (បារ, ខារ៉ាអូខេ, ផ្សព្វផ្សាយស្រាបៀរ, បៀរហ្គាឌិន, កាស៊ីណូ, ប៊ីយ៉ា, សណ្ឋាគារ , ផ្ទះសំណាក់, ម៉ាស្សា...), មាន ១១% ក្នុងចំណោមក្រុមយុវវ័យជាស្ត្រីទាំងអស់ ។

យើងសំគាល់ឃើញថា ការហៅទូរសព្ទ័ពីស្ត្រីចូលមកកម្មវិធីឥន្ទធនូ មានកើនឡើងគួរអោយកត់សំគាល់ដែលមានត្រឹមតែ ២០%នៅឆ្នាំ ២០០៦ ហើយបានកើនឡើងដល់ ២៥% នៅឆ្នាំ ២០០៧, បន្ទាប់មក ២៨% នៅឆ្នាំ ២០០៨ និង ២០០៩, និងកើនរហូតដល់ ៣១% នៅក្នុងកំឡុងពេល ៦ ខែ នៅដើមឆ្នាំ ២០១០នេះ។

រូបភាពទី១ : បែងចែកតាមភេទនៃក្រុមយុវវ័យដែលបានហៅ ទូរស័ព្ទចូល ពីខែ មករា ដល់ខែ មិថុនា ឆ្នាំ ២០១០




## ប្រភេទនៃការហៅទូរសព្ទ័ចូល

៦២ % នៃក្រុមយុវវ័យដែលហៅទូរសព្ទ័ចូល គឺជាអតិថិជនដែលធ្លាប់បានហៅទូរសព្ទ័ ចូលមកដើម្បីសាកសួរពតិមាន និងពិភាក្សាពិគ្រោះយោបល់ តាមរយៈប្រព័ន្ធទូរស័ព្ទរបស់យើងរួចមកហើយពួកគាត់ជាអតិថិជនចាស់។ រីឯ ៣៦ % ទៀតគឺជាក្រុមយុវវ័យដែលទើបតែហៅទូរសព្ទ័ចូលជាលើក ដំបូង (រូបភាពទី ២) ។

រូបភាពទី២ : ប្រភេទនៃការហៅទូរសព្ទ័ចូលរបស់ក្រុមយុវវ័យអាយុ ១៥-២៤ ឆ្នាំ ពីខែ មករា ដល់ខែ មិថុនា ឆ្នាំ ២០១០




## ប្រភពនៃអ្នកហៅទូរសព្ទ័ចូល

ប្រព័ន្ធទូរស័ព្ទរបស់យើងបានទទួលការហៅចូលមកពីគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ជួនកាលមានការហៅចូលពីប្រជាជនកម្ពុជា ដែលរស់នៅបណ្តាប្រទេសជិតខាងផងដែរ។ ក្នុងកំឡុងពេលនេះស្មើរតែ១ ភាគ៤ នៃការហៅចូលមានប្រភពពីរាជធានីភ្នំពេញ (២៣%, រីឯ៣ភាគ៤ ទៀតមានប្រភពពីបណ្តាខេត្តផ្សេងៗ ដូចជា: ខេត្តកំពង់ចាម ១៥%, ខេត្តបាត់ដំបង ១0% ។ ក្រៅពីនេះក៏មានការហៅទូរសព្ទ័ចូលពីតំបន់ជនបទដាច់ស្រយាលខ្លះដែរ(រូបភាពទី៣)។ ខេត្តដែលមានប្រភពនៃការហៅចូលតិចជាង ៣ % មិនត្រូវបានបង្ហាញជូនក្នុងតារាងខាងក្រោមនេះទេ ។

រូបភាពទី៣: តំបន់ភូមិសាស្ត្រគ្របដណ្តប់ដែលមានការហៅទូរសព្ទ័ចូលពី ក្រុមយុវវ័យ
(២,២២១ នាក់) ពីខែមករា ដល់ខែមិថុនា ឆ្នាំ ២០១០




## ការពិភាក្សាអំពីការធ្វើតេស្តឈាមរកមេរោគអេដស៍

យុវវ័យភាគច្រើន ដែលបានទូរសព្ទ័ចូលមកកម្មវិធី គឺចង់ សាកសួរព័តិមានទាក់ទងនឹងការឆ្លងមេរោគអេដស៏តាមការរួមភេទ។ ប្រហែលជា ២០% នៃយុវវ័យដែលបានហៅចូលមកកម្មវិធី បានពិភាក្សាអំពីការធ្វើតេស្តឈាមរកមេរោគអេដស៏ក្នុងនោះ ១៨% បានប្រាប់ថាគេមិនទាន់បានធ្វើតេស្តឈាមរកមេរោគអេដស៏នៅឡើយទេ។ ក្នុងចំណោមអ្នកដែលពិភាក្សាអំពីការធ្វើតេស្តឈាមរកមេរោគអេសដ៏, ៣៥ % ជាស្ត្រីវ័យក្មេង។ ការពិភាក្សាអំពីការធ្វើតេស្តឈាមក្នុងចំណោមយុវវ័យមានការកើន ឡើងគួរអោយកត់សំគាល់បើប្រៀបធៀបទៅនឹងបីឆ្នាំកន្លងមកនេះដែលមាន ១២% នៅឆ្នាំ ២០០៧, ១៣% ឆ្នាំ ២០០៨ និង ២០ %នៅឆ្នាំ ២០០៩ រូបភាពទី ៤) ។

រូបភាពទី ៤ : ការពិភាក្សាអំពី ការធ្វើតេស្តឈាមរកមេរោគអេដស៏ក្នុងចំណោម
យុវវ័យចំនួន ២,២២១ នាក់ដែលបានហៅចូលកម្មវិធី
ពីខែ មករា ដល់ខែ មិថុនា ឆ្នាំ ២០១០




ប្រហែលជា ២៤% នៃយុវវ័យបានសាកសួរសំនួរទាក់ទងនឹងការប្រព្រឹត្តផ្លូវភេទ ។ ការលើកឡើងសំណួរទាក់ទងនឹងការរួមភេទតាមទ្វារមាសមាន៦៣%,ការរួមភេទតាមមាត់និងតាមទ្វារមាស៣,៦%, ការរួមភេទតាមមាត់ និងតាមរន្ធគូថ (១,៩ %),ការរួមភេទតាមមាត់ (១,១ %),និង ការរួមភេទតាមរន្ធគូថ (0,៦ %),។ ៧% នៃយុវវ័យដែលបានហៅ ទូរសព្ទ័ចូលបានប្រាប់ថា ពួកគាត់បានរួមភេទជាមួយដៃគូទៀងទាត់ និង ១៦% ទៀតរួមភេទជាមួយដៃគូមិនទៀងទាត់។
មានតែ ៥,៤%ប៉ុណ្ណោះបានប្រាប់ថា គាត់បានប្រើប្រាស់ស្រោមអនាម័យ ជាប់ជានិច្ចរាល់ពេលរួមភេទ (រូបភាពទី៥) ។

រូបភាពទី៥ : ក្រុមយុវវ័យដែលបានពិភាក្សាអំពីការប្រើប្រាស់ស្រោមអនាម័យ
ពីខែ មករា-មិថុនា ឆ្នាំ ២០១០




## ប្រធានបទនៃការពិភាក្សារបស់អតិថិជន

៨៩% នៃក្រុមយុវវ័យដែលទូរសព្ទ័ចូលមកចង់ពិភាក្សាជាមួយអ្នកផ្តល់ប្រឹក្សាអំពីបញ្ហាទាក់ទងនឹងជំងឺអេដស៏ក្នុងនោះ ២១% ពិភាក្សាអំពីការប្រើស្រោមអនាម័យដើម្បីបង្ការមេរោគអេដស៏ ហើយក្នុងនោះមាន២៣%ជាស្ត្រី។ ៩%ទៀតនៃយុវវ័យមានការចាប់អារម្មណ៏ លើការពិភាក្សាអំពី បញ្ហាទាក់ទងទៅនឹង សុខភាពបន្តពូជ និង ជំងឺកាមរោគ (រូបភាពទី៦) ។

យើងសង្កេតឃើញថា ៨៤%នៃអ្នកទូរសព្ទ័ចូលដោយសារគាត់ចង់បានព័តិមានពិតប្រាកដ ១៥%ទៀត គាត់ត្រូវការការផ្តល់ប្រឹក្សា,ការលើកទឹកចិត្ត និងត្រូវការពតិមានពីសេវាបញ្ជូន ទៅតាមបញ្ហារបស់គាត់រៀងខ្លួន។ សេវាធ្វើតេស្តឈាមរកមេរោគអេដស៏ដោយស្ម័គ្រនិងរក្សាការសំងាត់ និងសេវាព្យាបាលជំងឺកាមរោគជាសេវាដែលអតិថិជនត្រូវការជាងគេ ។

រូបភាពទី៦: ប្រធានបទដែលលើកមកពិភាក្សាក្នុងចំណោមយុវវ័យ
ចាប់ពីខែ មករា ដល់ខែ មិថុនា ឆ្នាំ ២០១០




សមាគមឥន្ទធនូ បានផ្តួចផ្តើមប្រើប្រាស់វិធីសាស្ត្រ ទៅអោយដល់ក្រុមយុវវ័យទាំងបុរស និងស្ត្រីដែលមានការប្រព្រឹត្តប្រឈមមុខនឹងគ្រោះថ្នាក់ដើម្បីជួយពួកគាត់ក្នុងការបង្ការការឆ្លងមេរោគអេដស៏ និងលើកទឹកចិត្តអោយទៅពិនិត្យ និងព្យាបាលជំងឺកាមរោគ, ទៅធ្វើតេស្តឈាមរកមេរោគអេដស៏អោយបានទាន់ពេលវេលា និងអាចទៅទទួលយកសេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៏និងជំងឺឳកាសនិយមអោយបានឆាប់រហ័ស។ នៅពេលអនាគតកម្មវិធីយើងខ្ញុំនឹងស្វែងរកយុទ្ធសាស្ត្រថ្មីៗទៀត ដើម្បីបង្កើនចំនួនអតិថិជនថ្មីតាមរយៈយុទ្ធនាការផ្សព្វផ្សាយបន្ថែមអោយបានកាន់តែច្រើន ដើម្បីរួមចំណែកផ្តល់ជូននូវព័តិមានត្រឹមត្រូវ និងជាក់លាក់ និងការផ្តល់ការពិភាក្សាពិគ្រោះយោបល់ និងលើកទឹកចិត្តប្រកបដោយប្រសិទ្ធិភាព ជូនដល់អតិថិជនគ្រប់ស្រទាប់វណ្ណៈដែលបានទូរសព្ទ័ចូលមកកម្មវិធីយើងខ្ញុំ។
យើងខ្ញុំសង្ឃឹមថា ព័តិមាននេះពិតជាមានប្រយោជន៏ដល់អង្គការជាដៃគូទាំងអស់, ដោយសារតែវាបានបញ្ជាក់ស៊ីជំរៅអំពី តំរូវការរបស់ក្រុមប្រជាជនប្រឈមមុខ និងអ្នកប្រើប្រាស់សេវា ។


សំរាប់ព័តិមានបន្ថែម សូមទំនាក់ទំនង
សមាគមឥន្ទធនូ តាមសារអេឡិចត្រូនិក: info@inthanou.org,
វិតាមគេហទំព័រ: http://www.inthanou.org, ទូរស័ព្ទលេខ: (+855-23)986-240



ព្រឹត្តិប័ត្រត្រូវបានឧបត្ថម្ភទាំងបច្ចេកទេស និង ថវិកា ដោយអង្គការ UNICEF